ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

លេខ : ..........២០៨..........បទ.ប្រក

".....ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព"

# ប្រកាស

## ស្តីពី

## ការទទួលស្គាល់យថាប្រភេទ (TYPE APPROVAL) លើបរិក្ខារវិទ្យុគមនាគមន៍ និងបរិក្ខារទូរគមនាគមន៍

~~~~~~~~~~~~

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ២០/អនក្រ/បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ០៥/អនក្រ/បក ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ១៩៩៧ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីស្តីពីប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៦៦/អនក្រ/បក ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៨៦អនក្រ.បក ចុះថ្ងៃទី ១៩ខែ សីហា ឆ្នាំ ២០០២ ស្តីពីការកែសំរួល និងបំពេញបន្ថែមនាយកដ្ឋានមួយចំនួន នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៣ ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាល និង បណ្តុះបណ្តាលទៅជាអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញប្រកាសលេខ ០៧២ ប.ទ.ប្រក. ស្តីពីការគ្រប់គ្រងបរិក្ខារវិទ្យុគមនាគមន៍ និងថ្លៃសេវាប្រើប្រាស់រលកអាកាសវិទ្យុ
~~~~~~~~~~~~

- បានឃើញសេចក្ដីសំរេចលេខ ១៥៤ សសរ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីស្ដីពីបំរាមនានុក្រមគ្រប់គ្រងតម្លៃ ។

# សម្រេច

**ប្រការ ១ :** រាល់បរិក្ខារវិទ្យុគមនាគមន៍ និងបរិក្ខារទូរគមនាគមន៍ត្រូវមានការទទួលស្គាល់យថាប្រភេទ **(Type Approval)** ពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍មុននឹងដាក់អោយធ្វើចរាចរលើទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ២ :** រាល់បទបញ្ញត្តិនៃប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវទុកជា និរាករណ៍ ។

**ប្រការ ៣ :** អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍ អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋានពាក់ព័ន្ធ និងគ្រប់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ រាជធានី-ខេត្ត ក្រោមឱវាទក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវទទួលបន្ទុកអនុវត្តតាមតួនាទី និង ភារកិច្ចនូវប្រកាសនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

**ប្រការ ៤ :** ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី២៤ ខែ ៦ ឆ្នាំ២០១០

**រដ្ឋមន្ត្រី**

 សូ-ឃុន

**កន្លែងទទួល**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភាជាតិ
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងផែនការ
  "ដើម្បីជ្រាបជាព័ត៌មាន"
- ដូចប្រការ ៣
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ